ចំណេះដឹងគ្រប់វិនាទី

កំរងវិញ្ញាសាគណិតវិទ្យា

$$\frac{4-x}{1986}+\frac{3-x}{1987}+\frac{2-x}{1988}+\frac{1-x}{1989}=-$$

$$\frac{1}{1+a+ab}+\frac{1}{1+b+bc}+\frac{1}{1+c+ca}=$$

រួមមាន៖

វិញ្ញាសាប្រឡងជ្រើសរើសគ្រូមធ្យមសិក្សា

វិញ្ញាសាប្រឡងជ្រើសរើសគ្រូបឋមសិក្សា

វិញ្ញាសាត្រៀមប្រឡងផ្សេងៗ..........

ស្របតាមកម្មវិធីសិក្សាថ្មី

www.facebook.com/7khmer
Fb page : Entertainment And Knowledge

វិញ្ញាសាទី១

ប្រឡងជ្រើសរើសគ្រូមធ្យមសិក្សាបឋមភូមិ

សម័យប្រឡង: ១១ តុលា ២០០២

រយៈពេល: ២ ម៉ោង

1. ក. ដោះស្រាយសមីការក្នុងសំណុំចំនួនកុំផ្លិច $x^2 - 2x + 5 = 0$

ខ. គណនាឫសការេនៃចំនួនកុំផ្លិច $8-6i$ ។

2. ក. គណនាអាំងតេក្រាលមិនកំនត់

$$I = \int \cos^2 x dx \qquad J = \int x \sin x dx$$

ខ. រកព្រីមីទីវនៃអនុគមន៍ $f(x) = 2x(x^3+1)$ ដោយដឹងថាព្រីមីទីវនៃអនុគមន៍នេះស្មើនឹង 3 កាលណា $x=-1$ ។

3. គេអោយអនុគមន៍ $f(x) = \dfrac{x-1}{|x|+1}$

ក. សិក្សាភាពជាប់នៃអនុគមន៍ f ត្រង់ចំណុច $x=0$

ខ. តើអនុគមន៍ f មានដេរីវេត្រង់ចំណុច $x=0$ ដែរឬទេ ?

4. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): y''+4y'+4y=0$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ខ. គេអោយសមីការឌីផេរ៉ង់ស្យែល $(F): y''+4y'+4y=-4x$ ។

កំណត់ចំនួនពិត a និង b ដែលអនុគមន៍ $\varphi : x \mapsto ax+b$

ជាចំលើយនៃ (F) ។

5. ក្នុងតំរុយអរតូណរម៉ាល់ $(0;\vec{i};\vec{j};\vec{k})$ គេមានចំណុច $A(2;2;2)$

$B(2;0;1)$ និង $C(4;1;-1)$

ក. បង្ហាញថាត្រីកោណ ABC ជាត្រីកោណកែងត្រង់ B

ខ. រកសមីការប្លង់ដែលកាត់តាមបីចំណុចនេះ ។

6. គេអោយអនុគមន៍ $y=\dfrac{1}{(x-1)^2}+\dfrac{1}{(x+1)^2}$

ក. សិក្សាទិសដៅអថេរភាព និង សង់ខ្សែកោង (c) តាងក្រាបនៃអនុគមន៍

ខ. គណនាផ្ទៃក្រឡានៃប្លង់ខណ្ឌដោយខ្សែកោង (c) បន្ទាត់ $x=2$ និង $x=5$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចំលើយ

1. ក. ដោះស្រាយសមីការក្នុងសំណុំចំនួនកុំផ្លិច

$$x^2 - 2x + 5 = 0$$

$$\Delta' = 1 - 5 = -4 = (2i)^2$$

$$\Rightarrow x_1 = \frac{-b' - \sqrt{\Delta'}}{a} = 1 - 2i$$

$$x_2 = \frac{-b' + \sqrt{\Delta'}}{a} = 1 + 2i$$

ដូចនេះ $\boxed{x_1 = 1 - 2i ; x_2 = 1 + 2i}$

ខ. គណនាឫសការេនៃចំនួនកុំផ្លិច $8 - 6i$

តាង $Z = 8 - 6i$

$$= 9 - 6i - 1$$

$$= 3^2 - 2 \cdot 3i + i^2$$

$$= (3 - i)^2$$

គេបាន $\sqrt{Z} = \sqrt{(3 - i)^2}$

$$\Rightarrow Z_1 = 3 - i \;;\; Z_2 = -(3 - i) = -3 + i$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដូចនេះ $Z_1 = 3 - i ; Z_2 = -3 + i$

2. ក. គណនាអាំងតេក្រាលមិនកំនត់

$$I = \int \cos^2 x dx = \int \frac{1+\cos 2x}{2} dx$$

$$= \frac{1}{2}\int (1+\cos 2x) dx = \frac{1}{2}(x + \frac{1}{2}\sin 2x) + c$$

ដូចនេះ $I = \frac{1}{2}(x + \frac{1}{2}\sin 2x) dx + c$

$$J = \int x \sin x dx$$

តាង $u = x \Rightarrow du = dx$

$$dv = \sin x dx \Rightarrow v = -\cos x$$

តាមរូបមន្ត $\int u dv = uv - \int v du$

គេបាន: $J = -x\cos x - \int -(\cos x) dx$

$$= -x\cos x + \sin x + c$$

ដូចនេះ $J = -x\cos x + \sin x + c$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ខ. រកព្រីមីទីវនៃ f

$$f(x)=2x(x^3+1)$$

ព្រីមីទីវនៃf គឺ F កំនត់ដោយ $F(x)=\int f(x)dx$

$$F(x)=\int 2x(x^3+1)dx$$
$$=\int(2x^4+2x)dx$$
$$=\frac{2}{5}x^5+x^2+c$$

$$F(x)=\frac{2}{5}x^5+x^2+c$$

ដោយ $F(-1)=3 \Leftrightarrow \frac{2}{5}(-1)^5+(-1)^2+c=3$

$$-\frac{2}{5}+1+c=3$$

$$c=3+\frac{2}{5}-1$$

$$c=\frac{15+2-5}{5}$$

$$c=\frac{12}{5}$$

www.facebook.com/7khmer

Fb page : Entertainment And Knowledge

ដូចនេះ $F(x)=\frac{2}{5}x^5+x^2+\frac{12}{5}$

3. គេអោយអនុគមន៍ $f(x)=\frac{x-1}{|x|+1}$

ក. សិក្សាភាពជាប់នៃ f ត្រង់ $x=0$

គេមាន: $f(0)=-1$

$$\lim_{x\to 0^-} f(x)=\lim_{x\to 0^-}\left(\frac{x-1}{|x|+1}\right)$$

$$=\lim_{x\to 0^-}\left(\frac{x-1}{-x+1}\right)=\lim_{x\to 0^-}\frac{-(-x+1)}{(-x+1)}$$

$$=\lim_{x\to 0^-}(-1)=-1$$

$$\lim_{x\to 0^+} f(x)=\lim_{x\to 0^+}\frac{x-1}{|x|+1}$$

$$=\lim_{x\to 0^+}\left(\frac{x-1}{x+1}\right)=-1$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដោយ $\lim_{x\to 0^-} f(x) = \lim_{x\to 0^+} f(x) = f(0) = -1$

ដូចនេះ អនុគមន៍ f ជាប់ត្រង់ចំណុច $x=0$ ។

ខ, តើ f មានដេរីវេត្រង់ $x=0$ ដែរឬទេ ?

តាមរូបមន្តដេរីវេ $f'(x_0) = \lim_{h\to 0} \frac{f(h+x_0)-f(x_0)}{h}$

គេបាន: $f'_-(0) = \lim_{h\to 0^-} \frac{f(h)-f(0)}{h}$

$$= \lim_{h\to 0^-} \frac{\frac{h-1}{|h|+1}+1}{h} = \lim_{h\to 0^-} \frac{h-1+|h|+1}{h(|h|+1)}$$

$$= \lim_{x\to 0^-} \frac{h-1-h+1}{h(-h+1)} = \lim_{x\to 0^-} \left(\frac{0}{-h^2+h}\right) = 0$$

$$f'_+(0) = \lim_{x\to 0^+} \frac{f(h)-f(0)}{h}$$

$$= \lim_{x\to 0^+} \frac{h-1+|h|+1}{h(|h|+1)} = \lim_{x\to 0^+} \frac{h-1+h+1}{h(h+1)}$$

$$= \lim_{x\to 0^+} \frac{2h}{h(h+1)} = \lim_{x\to 0^+} \frac{2}{(h+1)} = 2$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដោយ $f'_-(0)=0\neq f'_+(0)=2$

ដូចនេះ អនុគមន៍ f មិនមានដេរីវេត្រង់ $x=0$ ទេ ។

4. ក. ដោះស្រាយសមីការ $(E): y''+4y'+4y=0$

មានសមីការសំគាល់: $r^2+4r+4=0$

$$\Delta'=b'^2-ac=2^2-4=0$$

$$\Rightarrow r_0=\frac{-b'}{a}=-2$$

គេបាន: $y=(Ax+B)e^{-2x},(A,B$ ជាចំនួនពិត$)$

ដូចនេះ

$y=(Ax+B)e^{-2x};(A,B\in R)$ ជាអនុគមន៍ចំលើយទូទៅនៃ (E)

ខ. កំណត់តម្លៃ a និង b

គេមាន $F(x): y''+4y'+4y=-4x$

ហើយ $\varphi(x)=ax+b$ ជាចំលើយនៃ (F)

$\Rightarrow \varphi'(x)=a$

$\Rightarrow \varphi''(x)=0$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

គេបាន: $\varphi''(x)+4\varphi'(x)+4\varphi(x)=-4x$

$$0+4a+4(ax+b)=-4x$$

$$0+4a+4ax+4b=-4x$$

$$4ax+4a+4b=-4x$$

$$\Rightarrow\begin{cases}4a=-4\\4a+4b=0\end{cases}\Leftrightarrow\begin{cases}a=-1\\b=1\end{cases}$$

ដូចនេះ $\boxed{a=-1;b=1}$

5. គេអោយចំណុច $A(2;2;2)$, $B(2;0;1)$ និង $C(4;1;-1)$

គេបាន: $\overrightarrow{BA}(0;2;1)$, $\overrightarrow{BC}(2;1;-2)$

ក. បង្ហាញថាត្រីកោណ ABC ជាត្រីកោណកែងត្រង់ B

$$\overrightarrow{BA}\cdot\overrightarrow{BC}=0\cdot2+2\cdot1+1(-2)$$

$$=2-2=0$$

ដោយ $\overrightarrow{BA}\cdot\overrightarrow{BC}=0$

$\Rightarrow BA\perp BC$ ត្រង់ B

ដូចនេះ $\boxed{\text{ត្រីកោណ } ABC \text{ ជាត្រីកោណកែងត្រង់ } B}$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ខ. រកសមីការប្លង់ដែលកាត់តាមបីចំណុចនេះ

$$\overrightarrow{BA}\times\overrightarrow{BC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 0 & 2 & 1\\ 2 & 1 & -2\end{vmatrix}=-5\vec{i}+2\vec{j}-4\vec{k}$$

ប្លង់ (ABC) កាត់តាម $A(2;2;2)$ ហើយកែងនឹងវ៉ិចទ័រ

$\overrightarrow{BA}\times\overrightarrow{BC}(-5;2;-4)$ កំណត់ដោយៈ

$$(ABC):-5(x-2)+2(y-2)-4(z-2)=0$$

$$-5x+2y-4z+10-4+8=0$$

$$-5x+2y-4z+14=0$$

$$5x-2y+4z-14=0$$

ដូចនេះ $\boxed{(ABC):5x-2y+4z-14=0}$

6. គេអោយ $y=\dfrac{1}{(x-1)^2}+\dfrac{1}{(x+1)^2}$

ក. សិក្សាទិសដៅអថេរភាព និង សង់ខ្សែកោង (c)

ដែនកំណត់ $D_f=R-\{-1;1\}$

ទិសដៅអថេរភាព

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$f'(x)=\frac{-2}{(x-1)^3}+\frac{-2}{(x+1)^3}$$

$$=\frac{-2(x+1)^3-2(x-1)^3}{(x^2-1)^3}$$

$$=\frac{-2(x^3+3x^2+3x+1)-2(x^3-3x^2+3x-1)}{(x^2-1)^3}$$

$$=\frac{-4x^3-12x}{(x^2-1)^3}=\frac{-4x(x^2+3)}{(x^2-1)^3}=\frac{-4x(x^2+3)}{(x^2-1)^2(x^2-1)}$$

បើ $f'(x)=0 \Leftrightarrow \frac{-4x(x^2+3)}{(x^2-1)^3}=0$ ដោយ $\frac{x^2+3}{(x^2-1)^2}>0$

$-4x=0$ $\forall x\in\mathbb{R}$

$\Rightarrow x=0$

x	$-\infty$		-1		0		1		$+\infty$
$-4x$		+		+	0	−		−	
x^2-1		+	0	−		−	0	+	
$f'(x)$		+	‖	−		+	‖	−	

www.facebook.com/7Khmer
Fb page : Entertainment And Knowledge

· តំលៃបរមាៈ $f(0)=2$

<u>គណនាលីមីត និង អាស៊ីមតូត</u>

$$\lim_{x\to\pm\infty} f(x)=\lim_{x\to\pm\infty}\left[\frac{1}{(x-1)^2}+\frac{1}{(x+1)^2}\right]=0$$

$$\lim_{x\to-1} f(x)=\lim_{x\to-1}\left[\frac{1}{(x-1)^2}+\frac{1}{(x+1)^2}\right]=+\infty$$

$$\lim_{x\to1} f(x)=\lim_{x\to1}\left[\frac{1}{(x-1)^2}+\frac{1}{(x+1)^2}\right]=+\infty$$

<u>អាស៊ីមតូត</u>

ដោយ $\lim_{x\to\pm\infty} f(x)=0$

$\Rightarrow$ បន្ទាត់ $y=0$ ជាអាស៊ីមតូតដេកនៃក្រាប (c) ។

ដោយ $\lim_{x\to-1} f(x)=+\infty$ និង $\lim_{x\to1} f(x)=+\infty$

$\Rightarrow$ បន្ទាត់ $x=-1$ និង $x=1$ ជាអាស៊ីមតូតឈរនៃក្រាប (c) ។

<u>តារាងអថេរភាពនៃ f</u>

www.facebook.com/7khmer
Fb page : Entertainment And Knowledge

x	$-\infty$		-1		0		1		$+\infty$
$f'(x)$		$+$	‖	$-$	0	$+$	‖	$-$	
$f(x)$	0	↗	$+\infty$ ‖ $+\infty$	↘	2	↗	$+\infty$ ‖ $+\infty$	↘	0

សង់ក្រាប (c)

តារាងតម្លៃលេខជំនួយ

x	-3	-2	2	3
y	0,3	1,1	1,1	0,3



www.facebook.com/7khmer
Fb page : Entertainment And Knowledge

ខ. គណនាក្រឡាផ្ទៃខណ្ឌដោយខ្សែកោង (c) បន្ទាត់ $x = 2$ និង $x = 5$

$$S = \int_2^5 f(x)dx = \int_2^5 \left[\frac{1}{(x-1)^2} + \frac{1}{(x+1)^2}\right]dx$$

$$= \left(\frac{-1}{x-1} + \frac{-1}{x+1}\right)\Big|_2^5 = \left(\frac{-1}{4} + \frac{-1}{6}\right) - \left(-1 + \frac{-1}{3}\right)$$

$$= \frac{-3-2}{12} - \frac{-12-4}{12} = \frac{-5}{12} + \frac{16}{12} = \frac{11}{12}$$

ដូចនេះ $\boxed{S = \frac{11}{12}}$ (ឯកតាផ្ទៃ)

www.facebook.com/7khmer
Fb page : Entertainment And Knowledge

វិញ្ញាសាទី២

ប្រឡងជ្រើសរើសគ្រូមធ្យមសិក្សាបឋមភូមិ

សម័យប្រឡងៈ ១៥ តុលា ២០០៣

រយៈពេលៈ ២ ម៉ោង

1. ក. សរសេរចំនួនកុំផ្លិចជាទម្រង់ត្រីកោណមាត្រ $1+i\sqrt{3}$

   ខ. ដោះស្រាយសមីការៈ $|Z|-Z=1+2i$ (Z ជាចំនួនកុំផ្លិច)

2. ក. គណនាដេរីវេនៃអនុគមន៍ $f(x)=x^5-2x^4+3x^3-2$

   ខ. កំណត់ដេរីវេទី n នៃអនុគមន៍ $h(x)=x^n$, $(n\in N^*)$

3. រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f(x)=\cos x$ ដែលខ្សែកោងតាង $F(x)$ កាត់តាមចំណុច $A(\frac{\pi}{2};0)$ ។

4. រកចំលើយសមីការឌីផេរ៉ង់ស្យែលផ្ទៀងផ្ទាត់លក្ខខណ្ឌដែលអោយៈ

   $y''-3y'+2y=0$, $y(1)=1$ និង $y'(1)=3$

5. គេអោយអនុគមន៍ $f(x)=\dfrac{ax^2+bx}{x^2-4x+3}$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ក. រកតម្លៃ a និង b ដោយដឹងថាអនុគមន៍មានតម្លៃអប្បបរមា ស្មើ 4 ត្រង់ $x=2$ ។

ខ. សិក្សាទិសដៅអថេរភាព និង សង់ខ្សែកោងនៃអនុគមន៍ $f(x)$ ចំពោះតម្លៃ a និង b ដែលរកឃើញ ។

6. ក្នុងតំរុយអរតូណរម៉ាល់ $(0;\vec{i};\vec{j};\vec{k})$ គេអោយប្លង់ពីរ (α) និង(β) មានសមីការរៀងគ្នាៈ

$$3x-2y+2z-5=0 \text{ និង } 4x+5y-z+1=0 \text{ ។}$$

ក. ស្រាយបញ្ជាក់ថាប្លង់ (α) អរតូកូណាល់ប្លង់ (β)

ខ. សរសេរសមីការប៉ារ៉ាម៉ែតបន្ទាត់ប្រសព្វនៃប្លង់ (α) និង (β)

7. គេអោយ $\overrightarrow{AC}=k\cdot\overrightarrow{CB}$ ដែល $k\neq-1$ ហើយ O គឺជាចំណុចមួយនៃប្លង់ ។ បង្ហាញថាៈ $\overrightarrow{OC}=\dfrac{\overrightarrow{OA}+k\cdot\overrightarrow{OB}}{k+1}$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចំលើយ

1. ក. សរសេរចំនួនកុំផ្លិចជាទម្រង់ត្រីកោណមាត្រ

$$1+i\sqrt{3}=2\left(\frac{1}{2}+i\frac{\sqrt{3}}{2}\right)=2\left(\cos\frac{\pi}{3}+i\sin\frac{\pi}{3}\right)$$

ដូចនេះ

$$\boxed{1+i\sqrt{3}=2\left(\cos\frac{\pi}{3}+i\sin\frac{\pi}{3}\right)}$$

ខ. ដោះស្រាយសមីការ $|Z|-Z=1+2i$

តាង $Z=a+bi\Rightarrow |Z|=\sqrt{a^2+b^2}$

គេបាន:

$$|Z|-Z=1+2i$$

$$\Leftrightarrow \sqrt{a^2+b^2}-(a+bi)=1+2i$$

$$\sqrt{a^2+b^2}-a-bi=1+2i$$

$$\Rightarrow \begin{cases}\sqrt{a^2+b^2}-a=1\\ -b=2\end{cases} \Leftrightarrow \begin{cases}\sqrt{a^2+b^2}=a+1\\ b=-2\end{cases}$$

នាំអោយ $\sqrt{a^2+(-2)^2}=a+1$

$$a^2+4=(a+1)^2$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$a^2+4=a^2+2a+1$$

$$2a=4-1=3$$

$$a=\frac{3}{2}$$

ដូចនេះ $Z=\frac{3}{2}-2i$ ជាឫសសមីការ

2. ក. រកដេរីវេនៃអនុគមន៍ f

$$f(x)=x^5-2x^4+3x^3-2$$

$$\Rightarrow f'(x)=5x^4-8x^3+9x^2$$

ដូចនេះ $f'(x)=5x^4-8x^3+9x^2$

ខ. កំណត់ដេរីវេទី n នៃអនុគមន៍ $h(x)=x^n$, $(n\in N^*)$

$$h(x)=x^n$$

$$\Rightarrow h'(x)=nx^{n-1}$$

$$h''(x)=n(n-1)x^{n-2}$$

$$h'''(x)=n(n-1)(n-2)x^{n-3}$$

គេបាន: $h^{(n)}=n(n-1)(n-2)\cdot\ldots\ldots\cdot[n-(n-1)]x^{n-n}$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$= n(n-1)(n-2)\cdot\ldots\ldots\cdot 1 = n!$$

ដូចនេះ $\boxed{h^{(n)} = n!}$, $(n \in N^*)$

3. រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f(x) = \cos x$

$$F(x) = \int f(x)dx$$
$$= \int \cos x dx$$
$$= \sin x + c$$

ដោយ $F(x)$ កាត់តាមចំណុច $A(\frac{\pi}{2};0)$

$$\Rightarrow F(\frac{\pi}{2}) = 0$$

$$\sin\frac{\pi}{2} + c = 0$$

$$1 + c = 0 \Rightarrow c = -1$$

ដូចនេះ $\boxed{F(x) = \sin x - 1 \text{ ជាព្រីមីទីវនៃ } f}$

4. រកចំលើយនៃសមីការឌីផេរ៉ង់ស្យែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

$y''-3y'+2y = 0$ មានសមីការសំគាល់ $r^2 - 3r + 2 = 0$

www.facebook.com/7khmer

Fb page : Entertainment And Knowledge

ចូលរាង $a+b+c=0$ គឺ $1-3+2=0$

$$\Rightarrow r_1=1; r_2=\frac{c}{a}=2$$

គេបាន: $y=Ae^{x}+Be^{2x}, (A,B\in R)$

$$\Rightarrow y'=Ae^{x}+2Be^{2x}$$

ដោយគេដឹងថា $\begin{cases} y(1)=1 \\ y'(1)=3 \end{cases}$

$$\Rightarrow \begin{cases} Ae+Be^{2}=1 \\ Ae+2Be^{2}=3 \end{cases} \Leftrightarrow \begin{cases} A=-e^{-1} \\ B=2e^{-2} \end{cases}$$

គេបាន: $y=-e^{-1}\cdot e^{x}+2e^{-2}\cdot e^{2x}$

$$=-e^{x-1}+2e^{2x-2}$$

ដូចនេះ

$y=-e^{x-1}+2e^{2x-2}$ ជាចំលើយនៃសមីការឌីផេរ៉ង់ស្យែល

5. គេអោយអនុគមន៍ $f(x)=\dfrac{ax^{2}+bx}{x^{2}-4x+3}$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ក. រកតម្លៃ a និង b

$$f'(x)=\frac{(2ax+b)(x^2-4x+3)-(ax^2+bx)(2x-4)}{(x^2-4x+3)^2}$$

ដោយ f មានតម្លៃអប្បបរមាស្មើ 4 ត្រង់ $x=2$

គេបាន $\begin{cases} f'(2)=0 \\ f(2)=4 \end{cases} \Leftrightarrow \begin{cases} -(4a+b)=0 \\ -(4a+2b)=4 \end{cases}$ (ព្រោះ $f''(x_0)>0$)

$\Leftrightarrow \begin{cases} -4a-b=0 \\ 4a+2b=-4 \end{cases} \Leftrightarrow \begin{cases} a=1 \\ b=-4 \end{cases}$

ដូចនេះ $\boxed{a=1; b=-4}$

ខ. សិក្សាទិសដៅអថេរភាព និង សង់ខ្សែកោងនៃអនុគមន៍ f

$$f(x)=\frac{x^2-4x}{x^2-4x+3}$$

ដែនកំណត់ $D_f=R-\{1;3\}$

ទិសដៅអថេរភាព

$$f'(x)=\frac{(2x-4)(x^2-4x+3)-(2x-4)(x^2-4x)}{(x^2-4x+3)^2}$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$= \frac{(2x-4)(x^2-4x+3-x^2+4x)}{(x^2-4x+3)^2}$$

$$= \frac{3(2x-4)}{(x^2-4x+3)^2}$$

ដោយ $(x^2-4x+3)^2 \rangle 0 \ , \forall x \in D_f$

នោះ $f'(x)$ មានសញ្ញាដូច $2x-4$ ។

បើ $f'(x)=0 \Leftrightarrow 2x-4=0 \Rightarrow x=2$

សញ្ញានៃ $f'(x)$

x	$-\infty$	1		2		3	$-\infty$
$f'(x)$	$-$	|	$-$	0	$+$	|	$+$

តម្លៃបរមាៈ $x=2$; $f(2)=4$

លីមីត និង អាស៊ីមតូត

$$\lim_{x\to\pm\infty} f(x) = \lim_{x\to\pm\infty} \frac{x^2-4x}{x^2-4x+3} = \lim_{x\to\pm\infty} \frac{x^2}{x^2} = 1$$

$\Rightarrow$ បន្ទាត់ $y=1$ ជាអាស៊ីមតូតដេកនៃក្រាប (c) ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$\lim_{x\to1} f(x)=\lim_{x\to1}\frac{x^2-4x}{x^2-4x+3}=\frac{-3}{0}=\pm\infty$$

$$\lim_{x\to3} f(x)=\lim_{x\to3}\frac{x^2-4x}{x^2-4x+3}=\frac{-3}{0}=\pm\infty$$

ដោយ $\lim_{x\to1} f(x)=\pm\infty$ និង $\lim_{x\to3} f(x)=\pm\infty$

$\Rightarrow$ បន្ទាត់ $x=1$ និង $x=3$ ជាអាស៊ីមតូតឈរនៃក្រាប (c) ។

តារាងអថេរភាពនៃ f

x	$-\infty$		1		2		3		$+\infty$
$f'(x)$		$-$	‖	$-$	0	$+$	‖	$+$	
$f(x)$	1	$\searrow$	$-\infty$ ‖ $+\infty$	$\searrow$	4	$\nearrow$	$+\infty$ ‖ $-\infty$	$\nearrow$	1

សង់ខ្សែកោង (c)

រក $(c)\cap(x'ox)$: $y=0$: $x^2-4x=0$

$$\Rightarrow x=0; x=4$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge



6. គេមាន $(\alpha): 3x - 2y + 2z - 5 = 0$

$(\beta): 4x + 5y - z + 1 = 0$

ស្រាយបញ្ជាក់ថាប្លង់ (α) និង ប្លង់ (β) អរតូកូណាល់នឹងគ្នា

ដោយប្លង់ (α) មានវ៉ិចទ័រណរម៉ាល់ $\vec{n}_1(3;-2;2)$

ប្លង់ (β) មានវ៉ិទ័រណរម៉ាល់ $\vec{n}_2(4;5;-1)$

គេបាន $\vec{n}_1 \cdot \vec{n}_2 = 12 - 10 - 2 = 0$

ដោយ $\vec{n}_1 \cdot \vec{n}_2 = 0 \Rightarrow \vec{n}_1 \perp \vec{n}_2 \quad (1)$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ម្យ៉ាងទៀត $\begin{cases}(\alpha)\perp\vec{n}_1\\(\beta)\perp\vec{n}_2\end{cases}$ (2)

តាម (1) និង (2) បង្ហាញថា $(\alpha)\perp(\beta)$

ដូចនេះ បង្ហាញថាប្លង់ (α) អរតូកូណាល់នឹងប្លង់ (β) ។

ខ. សរសេរសមីការបន្ទាត់ប៉ារ៉ាម៉ែតប្រសព្វនៃប្លង់ (α) និងប្លង់ (β)

$$\begin{cases}3x-2y+2z-5=0\\4x+5y-z+1=0 \quad \times 2\end{cases}$$

$$11x+8y-3=0$$

តាង $x=t\ ;\ (t\in R)$

$$\Rightarrow y=\frac{3-11t}{8}=\frac{3}{8}-\frac{11}{8}t$$

$$4t+5\left(\frac{3}{8}-\frac{11}{8}t\right)-z+1=0$$

$$4t+\frac{15}{8}-\frac{55}{8}t-z+1=0$$

$$\frac{32t-55t}{8}-z+\frac{15+8}{8}=0$$

$$\frac{-23t}{8}-z+\frac{23}{8}=0$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$z=\frac{23}{8}-\frac{23}{8}t$$

ដូចនេះ សមីការបន្ទាត់ប៉ារ៉ាម៉ែតគឺ

$$(d): x=t; y=\frac{3}{8}-\frac{11}{8}t; z=\frac{23}{8}-\frac{23}{8}t, (t\in R)$$

7. បង្ហាញថា $\overrightarrow{OC}=\dfrac{\overrightarrow{OA}+k\cdot\overrightarrow{OB}}{k+1}$

គេមាន $\overrightarrow{AC}=k\cdot\overrightarrow{CB}$

$$\overrightarrow{AO}+\overrightarrow{OC}=k\cdot(\overrightarrow{CO}+\overrightarrow{OB})$$

$$\overrightarrow{OC}-\overrightarrow{OA}=k(\overrightarrow{OB}-\overrightarrow{OC})$$

$$\overrightarrow{OC}-\overrightarrow{OA}=k\cdot\overrightarrow{OB}-k\cdot\overrightarrow{OC}$$

$$k\cdot\overrightarrow{OC}+\overrightarrow{OC}=\overrightarrow{OA}+k\cdot\overrightarrow{OB}$$

$$(k+1)\overrightarrow{OC}=\overrightarrow{OA}+k\cdot\overrightarrow{OB}$$

$$\Rightarrow \overrightarrow{OC}=\frac{\overrightarrow{OA}+k\cdot\overrightarrow{OB}}{k+1}$$

ដូចនេះ បង្ហាញថា

$$\overrightarrow{OC}=\frac{\overrightarrow{OA}+k\cdot\overrightarrow{OB}}{k+1}$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

វិញ្ញាសាទី៣

ប្រឡងជ្រើសរើសគ្រូមធ្យមសិក្សាបឋមភូមិ

សម័យប្រឡង: ១៧ តុលា ២០០៤

រយៈពេល: ២ ម៉ោង

1. ក. រកចំនួនពិត x និង y ដើម្បីបំពេញលក្ខខណ្ឌ:

$$(x+y)+(2x-y)i = 2-5i$$

ខ. ចូរសរសេរ $(1+i\sqrt{3})^{10}$ ជារាង $a+bi$ ។

2. ក. រកក្រឡាផ្ទៃ S ដែលកំណត់ដោយខ្សែកោង: $y=\sin x$ ដោយ $0 \le x \le 3\pi$ ជាមួយអ័ក្សអាប់ស៊ីស ។

*ខ. គណនាអាំងតេក្រាលមិនកំណត់:

$$I = \int x\cos x dx \quad , \quad J = \int \frac{5}{5x-7} dx$$

3. ✓ក្នុងតំរុយអរតូណរម៉ាល់ គេមានចំណុចបី : $A(1;4;2)$, $B(2;1;3)$ និង $C(-2;2;-1)$ ។ គណនាផ្ទៃក្រឡា ΔABC រួចបង្ហាញថាត្រីកោណ ABC ជាត្រីកោណកែង ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

4. គេសរសេរលេខ 1;2;3;4;5;6;7;8;9 រៀងគ្នាលើកាត់ 9 ។ គេចាប់យកកាត់នេះម្តងមួយៗពីផង់ចំនួន3 កាត់ មកតំរៀបតាមលំដាប់ដែលចាប់បាន ។

ក. រកប្រូបាបដើម្បីអោយកាត់ទាំងបីដែលចាប់បាន បង្កើតបានជាចំនួន 123 ។

ខ. រកប្រូបាបដើម្បីអោយកាត់ទាំងបីដែលចាប់បាន បង្កើតបានជាចំនួនចែកដាច់នឹង 125 ។

5. គណនាតម្លៃអតិបរមា អប្បបរមា និង ចំណុចរបត់របស់ខ្សែកោងតាងអនុគមន៍ $y = 3xe^{-x^2}$ រួចសង់ខ្សែកោង (c) តាងអនុគមន៍

6. គេអោយសមីការឌីផេរ៉ង់ស្យែល $(E): y'+2y = x^2$ ។

ក. កំណត់អនុគមន៍ពហុធា g មានសមីការដឺក្រេទី2 ជាចំលើយសមីការ (E) ។

ខ. បង្ហាញថាអនុគមន៍ f ជាចំលើយនៃសមីការ (E) លុះត្រាតែ $f-g$ ជាចំលើយនៃសមីការ $(E'): y'+2y = 0$ ។

គ. ដោះស្រាយសមីការ(E') ។ ទាញរកចំលើយនៃសមីការ (E) ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចំលើយ

1. ក. រកចំនួនពិត x និង y

គេមាន $(x+y)+(2x-y)i=2-5i$

$$\Rightarrow \begin{cases} x+y=2 \\ 2x-y=-5 \end{cases} +$$

$$3x=-3$$

$$\Rightarrow x=-1$$

$$\Rightarrow y=2+1=3$$

ដូចនេះ $\boxed{x=-1; y=3}$

ខ. សរសេរ $(1+i\sqrt{3})^{10}$ ជារាង $a+bi$

គេមាន $1+i\sqrt{3}=2\left(\frac{1}{2}+i\frac{\sqrt{3}}{2}\right)$

$$=2\left(\cos\frac{\pi}{3}+i\sin\frac{\pi}{3}\right)$$

គេបាន $(1+i\sqrt{3})^{10}=\left[2\left(\cos\frac{\pi}{3}+i\sin\frac{\pi}{3}\right)\right]^{10}$

$$=2^{10}\left(\cos\frac{10\pi}{3}+i\sin\frac{10\pi}{3}\right)$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$=2^{10}\left[\cos(3\pi+\frac{\pi}{3})+i\sin(3\pi+\frac{\pi}{3})\right]$$

$$=2^{10}\left(-\cos\frac{\pi}{3}-i\sin\frac{\pi}{3}\right)$$

$$=2^{10}\left(-\frac{1}{2}-i\frac{\sqrt{3}}{2}\right)$$

$$=-2^9-2^9\sqrt{3}i$$

ដូចនេះ $\boxed{(1+i\sqrt{3})^{10}=-2^9-2^9\sqrt{3}i}$

2. ក. រកផ្ទៃក្រឡា S

$$S=\int_0^{3\pi}|\sin x|dx$$

x	0	$\frac{\pi}{2}$	π	$\frac{3\pi}{2}$	2π	$\frac{5\pi}{2}$	3π
$\lvert\sin x\rvert$	$\sin x$	$\sin x$	$-\sin x$	$-\sin x$	$\sin x$	$\sin x$	

គេបាន $S=\int_0^{3\pi}|\sin x|dx=\int_0^{\pi/2}\sin xdx+\int_{\pi/2}^{\pi}\sin xdx$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$-\int_{\pi}^{3\pi/2}\sin x\,dx-\int_{3\pi/2}^{2\pi}\sin x\,dx+\int_{2\pi}^{5\pi/2}\sin x\,dx$$

$$+\int_{5\pi/2}^{3\pi}\sin x\,dx=(-\cos x)\Big|_{0}^{\pi/2}+(-\cos x)\Big|_{\pi/2}^{\pi}$$

$$-(-\cos x)\Big|_{\pi}^{3\pi/2}-(-\cos x)\Big|_{3\pi/2}^{2\pi}+(-\cos x)\Big|_{2\pi}^{5\pi/2}$$

$$+(-\cos x)\Big|_{5\pi/2}^{3\pi}=(0+1)+(1-0)-(0-1)-(-1+0)$$

$$+(0+1)+(1+0)=1+1+1+1+1+1=6$$

ដូចនេះ $S=6$ (ឯកតាផ្ទៃ)

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ខ. គណនាអាំងតេក្រាលមិនកំណត់៖

$$I = \int x\cos x dx$$

តាង $u = x \Rightarrow du = dx$

$$dv = \cos x dx = v = \sin x$$

តាមរូបមន្ត $\int u dv = uv - \int v du$

គេបាន $I = \int x\cos x dx = x\sin x - \int \sin x dx$

$$= x\sin x + \cos x + c$$

ដូចនេះ $\boxed{I = x\sin x + \cos x + c}$

$$J = \int \frac{5}{5x-7} dx = \ln|5x-7| + c$$

ដូចនេះ $\boxed{J = \ln|5x-7| + c}$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

3. គណនាផ្ទៃក្រឡាត្រីកោណ ABC

គេមាន $\overrightarrow{AB}(1;-3;1)$, $\overrightarrow{AC}(-3;-2;-3)$

បាន $\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & -3 & 1\\ -3 & -2 & -3\end{vmatrix}=11\vec{i}-11\vec{j}$

$$S_{ABC}=\frac{1}{2}\left\|\overrightarrow{AB}\times\overrightarrow{AC}\right\|$$

ដោយ $\left\|\overrightarrow{AB}\times\overrightarrow{AC}\right\|=\sqrt{11^2+(-11)^2}=11\sqrt{2}$

$$\Rightarrow S_{ABC}=\frac{11\sqrt{2}}{2}$$

ដូចនេះ $S=\frac{11\sqrt{2}}{2}$ (ឯកតាផ្ទៃ)

បង្ហាញថាត្រីកោណ ABC ជាត្រីកោណកែង

$\overrightarrow{AB}\cdot\overrightarrow{AC}=-3+6-3=0$

ដោយ $\overrightarrow{AB}\cdot\overrightarrow{AC}=0\Rightarrow\overrightarrow{AB}\perp\overrightarrow{AC}$ ត្រង់ A

ដូចនេះ បង្ហាញថាត្រីកោណ ABC ជាត្រីកោណកែងត្រង់ A ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

4. ក. រកប្រូបាបដើម្បីអោយកាក់ទាំង3 ដែលចាប់បាន

បង្កើតបានជាចំនួន 123

តាង A ជាព្រឹត្តិការណ៍ចាប់បានកាក់ដែលចុះលេខ 1

B ជាព្រឹត្តិការណ៍ចាប់បានកាក់ដែលចុះលេខ 2

C ជាព្រឹត្តិការណ៍ចាប់បានកាក់ដែលចុះលេខ 3

ដោយព្រឹត្តិការណ៍ទាំងបីជាព្រឹត្តិការណ៍ទាក់ទងគ្នា

គេបាន: $P(123) = P(A) \times P\left(\frac{B}{A}\right) \times P\left(\frac{C}{AB}\right)$

$$= \frac{1}{9} \times \frac{1}{8} \times \frac{1}{7} = \frac{1}{504} = 0,002$$

<u>ដូចនេះ</u> $\boxed{P(123) = 0,002}$

ខ. រកប្រូបាបដើម្បីអោយកាក់ទាំង3 ដែលចាប់បាន

បង្កើតបានជាចំនួនដែលចែកដាច់នឹង 125

តាង E ជា " ព្រឹត្តិការណ៍ដែលចាប់បានកាក់ទាំង3 បង្កើតបានជាចំនួនដែលចែកដាច់នឹង 125 "

ដោយគេចាប់យកកាក់ម្តងមួយៗចំនួន 3 គេបាន:

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ករណីអាច $n(S)=C(9;1)\times C(8;1)\times C(7;1)$

$$=9\times8\times7=504$$

ចំនួនដែលចែកដាច់នឹង 125 គឺជាពហុគុណនៃ 125 ។ ចំនួនទាំងនោះរួមមាន: 125;250;375;500;625;750 និង 875 ។ ដោយគេដឹងថានៅលើកាក់គ្មានចុះលេខ0ទេ ដូច្នេះចំនួនដែលចែកដាច់នឹង125 មានតែ 125;375;625 និង 875 គេបាន:

ករណីស្រប $n(E)=4$

$$\Rightarrow P(E)=\frac{n(E)}{n(S)}=\frac{4}{504}=0,008$$

ដូចនេះ $\boxed{P(E)=0,008}$

5. គណនាតម្លៃអតិបរមា អប្បបរមា និងចំណុចរបត់ រួចសង់ក្រាប (c)

$y=f(x)=3xe^{-x^2}$

$\forall x\in R\Rightarrow f'(x)=3e^{-x^2}-2x\cdot3xe^{-x^2}$

$$=(3-6x^2)e^{-x^2}$$

ដោយ $e^{-x^2}\rangle0,\forall x\in R$ នោះ $f'(x)$ មានសញ្ញាដូច $3-6x^2$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

បើ $f'(x)=0$ នោះ $3-6x^2=0$

$$6x^2=3$$

$$x^2=\frac{1}{2}$$

$$x=\pm\frac{\sqrt{2}}{2}$$

សញ្ញានៃ $f'(x)$

x	$-\infty$		$\frac{-\sqrt{2}}{2}$		$\frac{\sqrt{2}}{2}$		$+\infty$
$f'(x)$		$-$	0	$+$	0	$-$	

ត្រង់ $x=\frac{-\sqrt{2}}{2}$ ធ្វើអោយ $f'(x)=0$ ហើយប្តូរសញ្ញាពី $(-)$ ទៅ $(+)$ នោះ $f(x)$ មានតម្លៃអប្បបរមាត្រង់ $x=\frac{-\sqrt{2}}{2}$ ។

$$f\left(\frac{-\sqrt{2}}{2}\right)=3\left(\frac{-\sqrt{2}}{2}\right)\cdot e^{-\left(\frac{-\sqrt{2}}{2}\right)^2}=-\frac{3}{2}\sqrt{2}\cdot e^{-\frac{1}{2}}$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដូចនេះ តម្លៃអប្បបរមាស្មើនឹង $-\frac{3}{2}\sqrt{2}\cdot e^{-\frac{1}{2}}$

ត្រង់ $x=\frac{\sqrt{2}}{2}$ ធ្វើអោយ $f'(x)=0$ ហើយប្តូរសញ្ញាពី $(+)$

ទៅ $(-)$ នោះ $f(x)$ មានតម្លៃអតិបរមាត្រង់ $x=\frac{\sqrt{2}}{2}$ ។

$$f\left(\frac{\sqrt{2}}{2}\right)=3\left(\frac{\sqrt{2}}{2}\right)e^{-\left(\frac{\sqrt{2}}{2}\right)^2}=\frac{3}{2}\sqrt{2}\cdot e^{-\frac{1}{2}}$$

ដូចនេះ តម្លៃអតិបរមាស្មើនឹង $\frac{3}{2}\sqrt{2}\cdot e^{-\frac{1}{2}}$

$$f''(x)=-12x\cdot e^{-x^2}+(3-6x^2)(-2x)e^{-x^2}$$
$$=-12x\cdot e^{-x^2}-(6x-12x^3)e^{-x^2}$$
$$=-18x\cdot e^{-x^2}+12x^3\cdot e^{-x^2}$$
$$=(-18x+12x^3)e^{-x^2}$$

បើ $f''(x)=0$; $(-18x+12x^3)e^{-x^2}=0$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$-18x+12x^3=0$$

$$x(-18+12x^2)=0$$

$$\Rightarrow\left[\begin{array}{l}x=0\\-18+12x^2=0\end{array}\right.$$

$$x^2=\frac{18}{12}=\frac{3}{2}$$

$$x=\pm\sqrt{\frac{3}{2}}$$

បើ $x=0; f(0)=0$

$$x=-\sqrt{\frac{3}{2}}; f\left(-\sqrt{\frac{3}{2}}\right)=-\frac{3\sqrt{3}}{\sqrt{2}}\cdot e^{-\frac{3}{2}}$$

$$x=\sqrt{\frac{3}{2}}; f\left(\sqrt{\frac{3}{2}}\right)=\frac{3\sqrt{3}}{\sqrt{2}}\cdot e^{-\frac{3}{2}}$$

ដូចនេះ ចំណុចរបត់នៃអនុគមន៍មានបីគឺ

$(0;0)$, $\left(-\sqrt{\frac{3}{2}};-\frac{3\sqrt{3}}{\sqrt{2}}\cdot e^{-\frac{3}{2}}\right)$ និង $\left(\sqrt{\frac{3}{2}};\frac{3\sqrt{3}}{\sqrt{2}}\cdot e^{-\frac{3}{2}}\right)$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

គណនាលីមីតចុងដែនកំណត់

$$\lim_{x\to-\infty} f(x) = \lim_{x\to-\infty} 3x\cdot e^{-x^2} = 0$$

$$\lim_{x\to+\infty} f(x) = \lim_{x\to+\infty} 3x\cdot e^{-x^2} = 0$$

ដោយ $\lim_{x\to\pm\infty} = 0 \Rightarrow$ បន្ទាត់ $y=0$ ជាអាស៊ីមតូតដេកនៃក្រាប (c)

តារាងអថេរភាព

x	$-\infty$		$\frac{-\sqrt{2}}{2}$		$\frac{\sqrt{2}}{2}$		$+\infty$
$f'(x)$		$-$	0	$+$	0	$-$	
$f(x)$	0	↘	f_m	↗	f_M	↘	0

សង់ក្រាប (c)

តម្លៃបរមា $-\frac{3}{2}\sqrt{2}\cdot e^{-\frac{1}{2}} = -1,27$; $\frac{3}{2}\sqrt{2}\cdot e^{-\frac{1}{2}} = 1,27$

www.facebook.com/7khmer
Fb page : Entertainment And Knowledge



6. គេអោយសមីការឌីផេរ៉ង់ស្យែល $(E): y'+2y = x^2$

ក. កំណត់អនុគមន៍ពហុធា g ដឺក្រេទី2 ជាចំលើយសមីការ(E)

$$g(x) = ax^2 + bx + c$$

$$\Rightarrow g'(x) = 2ax + b$$

ដោយ $g(x)$ ជាចំលើយនៃ(E) គេបាន:

$$g'(x) + 2g(x) = x^2$$

$$2ax + b + 2(ax^2 + bx + c) = x^2$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$2ax^2 + (2a+2b)x + b + 2c = x^2$$

$$\Rightarrow \begin{cases} 2a = 1 \\ 2a + 2b = 0 \\ b + 2c = 0 \end{cases} \Leftrightarrow \begin{cases} a = \dfrac{1}{2} \\ b = -\dfrac{1}{2} \\ c = \dfrac{1}{4} \end{cases}$$

• គេបាន $g(x) = \dfrac{x^2}{2} - \dfrac{x}{2} + \dfrac{1}{4}$

ដូចនេះ $\boxed{g(x) = \dfrac{x^2}{2} - \dfrac{x}{2} + \dfrac{1}{4}}$

ខ. បង្ហាញថាអនុគមន៍ f ជាចំលើយនៃ (E) លុះត្រាតែ $f - g$ ជាចំលើយនៃសមីការ $(E'): y' + 2y = 0$

បើ $f - g$ ជាចំលើយនៃ(E') គេបាន៖

$$(f-g)' + 2(f-g) = 0$$

$$f' - g' + 2f - 2g = 0$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$f'+2f = g'+2g$$

$$\Rightarrow f = g$$

តែ g ជាចំលើយនៃ(E) នោះនាំអោយ f ក៏ជាចំលើយនៃ(E)ដែរ

<u>ដូចនេះ</u> បង្ហាញថាអនុគមន៍ f ជាចំលើយនៃ (E) លុះត្រាតែ $f-g$ ជាចំលើយនៃសមីការ(E') ។

គ. ដោះស្រាយសមីការ(E')

$$y'+2y=0$$

$$\Rightarrow y = ke^{-2x};\ \ (k \text{ ជាចំនួនពិត})$$

<u>ដូចនេះ</u> $y = ke^{-2x};(k\in R)$ ជាចំលើយទូទៅនៃសមីការ(E')

ទាញរកចំលើយនៃសមីការ(E)

ដោយ $f-g = ke^{-2x}$

$$f(x)-g(x) = ke^{-2x}$$

$$f(x) = \frac{x^2}{2}-\frac{x}{2}+\frac{1}{4}+ke^{-2x} \qquad (k\in R)$$

<u>ដូចនេះ</u> $f(x) = \frac{x^2}{2}-\frac{x}{2}+\frac{1}{4}+ke^{-2x}$ ជាចំលើយទូទៅនៃ(E)

www.facebook.com/7khmer
Fb page : Entertainment And Knowledge

វិញ្ញាសាទី៤

ប្រឡងជ្រើសរើសគ្រូមធ្យមសិក្សាបឋមភូមិ

សម័យប្រឡង: ០៣ វិច្ឆិកា ២០០៥

រយៈពេល: ២ ម៉ោង

1. ក. សរសេរចំនួនកុំផ្លិចជាទម្រង់ត្រីកោណមាត្រ $-2-2i$

ខ. ដោះស្រាយសមីការក្នុងសំណុំកុំផ្លិច

$$(2+i)x^2-(5-i)x+2-2i=0$$

2. ក. គណនាអាំងតេក្រាលមិនកំណត់

$$I=\int(2\sin x+3\cos x)dx \quad , \quad J=\int\frac{dx}{x^2-5x+6}$$

ខ. រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f(x)=x^2-e^x$

ដែល $F(0)=1$ ។

3. ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): y''-3y+2y=0$

ខ. រកចំលើយនៃសមីការ(E) បើគេដឹងថាអនុគមន៍ចំលើយមាន

www.facebook.com/7khmer
Fb page : Entertainment And Knowledge

អតិបរមាស្មើ 1 ត្រង់ $x=1$ ។

4. សរសេរសមីការប្លង់ (P) ដែលកាត់តាមចំណុច $M(1;2;-3)$ និងស្របជាមួយប្លង់ $(Q): 2x-4y-z+4=0$ រួចគណនាចម្ងាយរវាងប្លង់ទាំងពីរ ។

5. គេមានតួលេខ 0;1;2;3;4 ។ ដោយគ្រាន់តែប្រើតួលេខទាំងនោះ តើគេអាចបង្កើតចំនួនបានប៉ុន្មាន ដែលធំជាង 2000 ?
(បញ្ជាក់: ក្នុងចំនួននីមួយៗគ្មានតួលេខដដែលពីរដងទេ)

6. គេអោយអនុគមន៍ $f(x)=ae^{x}+b$ មានខ្សែកោង (c)

ក. កំណត់តម្លៃ a និង b ដើម្បីអោយខ្សែកោង (c) កាត់តាមគល់ O នៃតំរុយអរតូណរមេ និងបន្ទាត់ប៉ះខ្សែកោង (c) ត្រង់ចំណុចនេះជាបន្ទាត់ពុះទី1

ខ. សិក្សាទិសដៅអថេរភាព និង គូសខ្សែកោង(c) តាងអនុគមន៍ f ចំពោះតម្លៃ a និង b ដែលរកឃើញ

គ. គណនាផ្ទៃក្រឡាផ្នែកនៃប្លង់ដែលខណ្ឌដោយខ្សែកោង(c) អ័ក្ស $(x'ox)$ បន្ទាត់ $x=-1$ និង បន្ទាត់ $x=1$ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចំលើយ

1. ក. សរសេរចំនួនកុំផ្លិចជាទម្រង់ត្រីកោណមាត្រ $-2-2i$

តាង $Z=-2-2i$

$$=2\sqrt{2}\left(-\frac{\sqrt{2}}{2}-\frac{\sqrt{2}}{2}i\right)$$

$$=2\sqrt{2}\left(\cos\frac{5\pi}{4}+i\sin\frac{5\pi}{4}\right)$$

ដូចនេះ $$\boxed{Z=2\sqrt{2}\left(\cos\frac{5\pi}{4}+i\sin\frac{5\pi}{4}\right)}$$

ខ. ដោះស្រាយសមីការក្នុងសំណុំកុំផ្លិច

$$(2+i)x^2-(5-i)x+2-2i=0$$

$$\Delta=b^2-4ac=(5-i)^2-4(2+i)(2-2i)$$
$$=(25-10i-1)-4(4-4i+2i+2)$$
$$=24-10i-24+8i=-2i$$
$$=1-2i-1=(1-i)^2$$

$$\Rightarrow x_1=\frac{(5-i)-(1-i)}{2(2+i)}=\frac{4}{2(2+i)}$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$= \frac{2}{(2+i)} = \frac{2(2-i)}{4+1} = \frac{4-2i}{5}$$

$$\Rightarrow x_2 = \frac{(5-i)+(1-i)}{2(2+i)} = \frac{6-2i}{2(2+i)}$$

$$= \frac{3-i}{2+i} = \frac{(3-i)(2-i)}{4+1} = \frac{6-1-2i-3i}{5}$$

$$= \frac{5-5i}{5} = 1-i$$

<u>ដូចនេះ</u> $\boxed{x_1 = \frac{4-2i}{5} ; x_2 = 1-i}$

2. ក. គណនាអាំងតេក្រាលមិនកំណត់

$$I = \int(2\sin x + 3\cos x)dx$$

$$= -2\cos x + 3\sin x + c$$

<u>ដូចនេះ</u> $\boxed{I = -2\cos x + 3\sin x + c}$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$J=\int\frac{dx}{x^2-5x+6}$$

$$=\int\frac{dx}{(x-2)(x-3)}$$

$$=\int\left(\frac{-1}{x-2}+\frac{1}{x-3}\right)dx$$

$$=-\ln|x-2|+\ln|x-3|+c$$

$$=\ln\left|\frac{x-3}{x-2}\right|+c$$

ដូចនេះ $\boxed{J=\ln\left|\frac{x-3}{x-2}\right|+c}$

ខ. រកព្រីមីទីវ $F(x)$ នៃអនុគមន៍ $f(x)=x^2-e^x$

$$F(x)=\int f(x)dx$$

$$=\int(x^2-e^x)dx=\frac{1}{3}x^3-e^x+c$$

ដោយ $F(0)=1;\frac{1}{3}\cdot 0^3-e^0+c=1$

$$c-1=1\Rightarrow c=2$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដូចនេះ $F(x)=\frac{1}{3}x^3-e^x+2$

៣. ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល

$(E): y''-3y+2y=0$

មានសមីការសំគាល់ $r^2-3r+2=0$

ចូលរាង $a+b+c=0$ គឺ $1-3+2=0$

$\Rightarrow r_1=1; r_2=\frac{c}{a}=2$

គេបាន $y=Ae^x+Be^{2x}; (A,B\in R)$

ដូចនេះ $y=Ae^x+Be^{2x}$ ជាចំលើយទូទៅនៃសមីការ(E)

ខ. រកចំលើយនៃសមីការ(E)

$f(x)=Ae^x+Be^{2x}$

$\Rightarrow f'(x)=Ae^x+2Be^{2x}$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ដោយអនុគមន៍ចំលើយមានអតិបរមាស្មើ 1 ត្រង់ $x=1$

គេបាន: $\begin{cases} f'(1)=0 \\ f(1)=1 \end{cases}$

$$\Leftrightarrow \begin{cases} Ae+2Be^2=0 \\ Ae+Be^2=1 \quad \times(-1) \end{cases}$$

$$Be^2=-1 \Rightarrow B=-e^{-2}$$

$$\Rightarrow A=\frac{2}{e}=2e^{-1}$$

ដូចនេះ $\boxed{f(x)=2e^{x-1}-e^{2x-2}}$

4. សរសេរសមីការប្លង់(P)

$(Q): 2x-4y-z+4=0$ មានវ៉ិចទ័រណរម៉ាល់$\vec{n}(2;-4;-1)$

ដោយ $\left.\begin{array}{l} (Q)\perp \vec{n} \\ (P)\parallel(Q) \end{array}\right| \Rightarrow (P)\perp \vec{n}$

ប្លង់ (P) កាត់តាមចំណុច$M(1;2;-3)$ ហើយ

កែងនឹង$\vec{n}(2;-4;-1)$ កំណត់ដោយ:

$$(P): 2(x-1)-4(y-2)-(z+3)=0$$

$$2x-4y-z-2+8-3=0$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$2x-4y-z+3=0$$

ដូចនេះ $\boxed{(P): 2x-4y-z+3=0}$

គណនាចម្ងាយរវាងប្លង់ (P) និងប្លង់ (Q)

$$d((P),(Q)) = \|\vec{n}\|$$

គេមាន $\vec{n}(2;-4;-1)$

$$\Rightarrow \|\vec{n}\| = \sqrt{2^2+(-4)^2+(-1)^2}$$

$$= \sqrt{4+16+1} = \sqrt{21}$$

ដូចនេះ $\boxed{d((P),(Q)) = \sqrt{21}\text{ (ឯកតាប្រវែង)}}$

5. រកចំនួនករណីដែលគេអាចបង្កើតបានចំនួនដែលធំជាង 2000

-ខ្ទង់ពាន់មានជំរើស3 ករណី

-ខ្ទង់រយមានជំរើស4 ករណី

-ខ្ទង់ដប់មានជំរើស3 ករណី

-ខ្ទង់រាយមានជំរើស2 ករណី

គេបានចំនួនករណីសរុប$= 3\times 4\times 3\times 2 = 72$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

<u>ដូចនេះ</u> គេអាចបង្កើតចំនួនដែលធំជាង2000 បានចំនួន 72 របៀប ។

6. គេអោយអនុគមន៍ $f(x)=ae^{x}+b$ មានខ្សែកោង (c)

ក. កំណត់តំលៃ a និង b

$$f(x)=ae^{x}+b$$

$$\Rightarrow f'(x)=ae^{x}$$

ដើម្បីអោយខ្សែកោង (c) កាត់តាមគល់ O នៃតំរុយហើយ

បន្ទាត់ប៉ះនៃខ្សែកោង (c) ត្រង់ចំណុចនេះជាកន្លះបន្ទាត់ពុះទី1

លុះត្រាតែ:

$$\begin{cases} f(0)=0 \\ f'(0)=1 \end{cases} \Leftrightarrow \begin{cases} a+b=0 \\ a=1 \end{cases} \Leftrightarrow \begin{cases} a=1 \\ b=-1 \end{cases}$$

<u>ដូចនេះ</u> $\boxed{a=1;b=-1}$

ខ. សិក្សាទិសដៅអថេរភាព និងគូសខ្សែកោង (c) តាង f

$$(c):f(x)=e^{x}-1$$

<u>ដែនកំណត់</u> $D_f=R$

<u>ទិសដៅអថេរភាព</u>

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$f'(x)=e^x$$

ដោយ $e^x\rangle 0, \forall x \in D_f$ នោះ $f'(x)\rangle 0$ ជានិច្ច

លីមីត និង អាស៊ីមតូត

$$\lim_{x\to-\infty} f(x)=\lim_{x\to-\infty}(e^x-1)=-1$$

$\Rightarrow$ បន្ទាត់ $y=-1$ ជាអាស៊ីមតូតដេកនៃក្រាប (c) ។

$$\lim_{x\to+\infty} f(x)=\lim_{x\to+\infty}(e^x-1)=+\infty$$

តារាងអថេរភាពនៃ $f(x)$

x	$-\infty$		$+\infty$
$f'(x)$		$+$	
$f(x)$	-1	↗	$+\infty$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

សង់ខ្សែកោង (c)

តារាងតំលៃលេខជំនួយ

x	-1	1
y	$-0,6$	$1,7$



គ, គណនាក្រឡាផ្ទៃ S

$$S = S_1 + S_2 = \int_0^1 (e^x - 1)dx - \int_{-1}^0 (e^x - 1)dx$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$= \int_0^1 (e^x - 1)dx + \int_0^{-1} (e^x - 1)dx$$

$$= (e^x - x)\Big|_0^1 + (e^x - x)\Big|_0^{-1}$$

$$= (e - 1 - 1) + (e^{-1} + 1 - 1)$$

$$= e + \frac{1}{e} - 2$$

ដូចនេះ $S = \left(e + \frac{1}{e} - 2\right)$ (ឯកតាផ្ទៃ)

www.facebook.com/7khmer
Fb page : Entertainment And Knowledge

វិញ្ញាសាទី៥

ប្រឡងជ្រើសរើសគ្រូមធ្យមសិក្សាបឋមភូមិ

សម័យប្រឡង: ១៦ តុលា ២០០៧

រយៈពេល: ២ ម៉ោង

1. ក. កំណត់ចំនួនពិត x និង y ដើម្បីអោយ:

$$2xi - y = \frac{(3-2i)(1+i)}{i(1+2i)}$$

ខ. គេអោយ $Z = \cos\frac{2\pi}{9} + i\sin\frac{2\pi}{9}$ ។ សរសេរ $(1+Z)^4$

ជាទម្រង់ត្រីកោណមាត្រ ។

2. ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល

$$(E): g''(x) - 5g'(x) + 6g(x) = 0$$

ខ. កំណត់ចំលើយ $g(x)$ មួយនៃសមីការ (E) ដែល $g(0) = 0$

និង $g'(0) = 1$ ។

3. គេអោយអនុគមន៍ f កំណត់ដោយ $f(x) = \frac{1-\cos 2x}{x^2}$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចំពោះ $x \neq 0$ និង $f(0) = \ln(m-1)$ ។ គណនាលីមីត $f(x)$ កាលណា x ខិតជិតសូន្យ ។ កំណត់តម្លៃ m ដើម្បីអោយ f ជាអនុគមន៍ជាប់ត្រង់ $x = 0$ ។

4. ក្នុងថង់មួយមានឃ្លីស3 និងឃ្លីខ្មៅ5 ។ គេចាប់យកឃ្លីម្តងបីចេញពីក្នុងថង់ ។ រកប្រូបាបដែលគេអាចចាប់យកបានឃ្លីស2 និងឃ្លីខ្មៅ1

5. គេអោយអនុគមន៍ $g(x) = \dfrac{x^2 - 3x - 4}{x-2}$ មានក្រាប (c) ។

ក. កំណត់ចំនួនពិត $a;b;c$ ដើម្បីអោយ

$$g(x) = ax + b + \frac{c}{x-2} \quad \text{ចំពោះ } x \neq 2$$

ខ. រកសមីការអាស៊ីមតូតឈរ និងទ្រេតនៃក្រាប (c)

គ. បង្ហាញថាចំណុច $I(2;1)$ ជាផ្ចិតឆ្លុះនៃក្រាប (c)

6. ក្នុងលំហប្រដាប់ដោយតំរុយអរតូណរម៉ាល់វិជ្ជមាន $(0;\vec{i};\vec{j};\vec{k})$ គេអោយប្លង់(P)និងស្វ៊ែ (S) មានសមីការៈ

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$(P): x+2y+2z+5=0$

$(S): x^2+y^2+z^2-2x-4y+4z=0$

ក. កំណត់កូអរដោនេផ្ចិត និងកាំនៃស្វ៊ែ(S)

ខ. បង្ហាញថាប្លង់ (P) កាត់ស្វ៊ែ(S)

គ. រកសមីការបណ្តាប្លង់ស្របនឹងប្លង់ (P) ហើយប៉ះស្វ៊ែ(S) ។

ចំលើយ

1. ក. កំណត់ចំនួនពិតx និងy ដើម្បីអោយៈ

គេមាន $$2xi-y=\frac{(3-2i)(1+i)}{i(1+2i)}$$

$$=\frac{(3+3i-2i+2)}{(i-2)}$$

$$=\frac{(5+i)(i+2)}{1+4}$$

$$=\frac{5i+10-1+2i}{5}$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$= \frac{9+7i}{5} = \frac{9}{5} + \frac{7}{5}i$$

$$2xi - y = \frac{9}{5} + \frac{7}{5}i$$

$$\Rightarrow \begin{cases} 2x = \frac{7}{5} \\ -y = \frac{9}{5} \end{cases} \Leftrightarrow \begin{cases} x = \frac{7}{10} \\ y = -\frac{9}{5} \end{cases}$$

ដូចនេះ $\boxed{x = \frac{7}{10}; y = -\frac{9}{5}}$

ខ. សរសេរ $(1+Z)^4$ ជាទម្រង់ត្រីកោណមាត្រ

គេមាន: $1 + Z = 1 + \cos\frac{2\pi}{9} + i\sin\frac{2\pi}{9}$

$$= 2\cos^2\frac{\pi}{9} + 2i\sin\frac{\pi}{9}\cos\frac{\pi}{9}$$

$$= 2\cos\frac{\pi}{9}\left(\cos\frac{\pi}{9} + i\sin\frac{\pi}{9}\right)$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

គេបាន $(1+Z)^4=\left[2\cos\frac{\pi}{9}\left(\cos\frac{\pi}{9}+i\sin\frac{\pi}{9}\right)\right]^4$

$$=\left(2\cos\frac{\pi}{9}\right)^4\left(\cos\frac{\pi}{9}+i\sin\frac{\pi}{9}\right)^4$$

$$=16\cos^4\left(\frac{\pi}{9}\right)\left(\cos\frac{4\pi}{9}+i\sin\frac{4\pi}{9}\right)$$

<u>ដូចនេះ</u> $$\boxed{(1+Z)^4=16\cos^4\left(\frac{\pi}{9}\right)\left(\cos\frac{4\pi}{9}+i\sin\frac{4\pi}{9}\right)}$$

2. ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល

$$(E): g''(x)-5g'(x)+6g(x)=0$$

មានសមីការសំគាល់:

$$r^2-5r+6=0$$

$$\Delta=(-5)^2-4\times 6$$

$$=25-24=1$$

$$\Rightarrow r_1=\frac{5-1}{2}=2; r_2=\frac{5+1}{2}=3$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

គេបាន $g(x)=Ae^{2x}+Be^{3x},(A,B\in R)$

ដូចនេះ

$g(x)=Ae^{2x}+Be^{3x}$ ជាចំលើយទូទៅនៃសមីការ (E)

ខ. កំណត់ចំលើយ $g(x)$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ

$$g(x)=Ae^{2x}+Be^{3x},(A,B\in R)$$

$$\Rightarrow g'(x)=2Ae^{2x}+3Be^{3x}$$

តាមបំរាប់៖

$$\begin{cases} g'(0)=1 \\ g(0)=0 \end{cases}$$

គេបាន៖

$$\begin{cases} 2A+3B=1 \\ A+B=0 \quad \times(-3) \end{cases}$$

$$-A=1\Rightarrow A=-1$$

$$\Rightarrow B=1$$

ដូចនេះ $g(x)=-e^{2x}+e^{3x}$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

3. គណនាលីមីត $\lim_{x\to 0} f(x)$

$$\lim_{x\to 0} f(x) = \lim_{x\to 0}\frac{1-\cos 2x}{x^2}$$

$$= \lim_{x\to 0}\frac{2\sin^2 x}{x^2} = 2\lim_{x\to 0}\frac{\sin^2 x}{x^2} = 2\times 1 = 2$$

ដូចនេះ $\boxed{\lim_{x\to 0} f(x) = 2}$

កំណត់តម្លៃ m

ដើម្បីអោយ f ជាប់ត្រង់ $x=0$ លុះត្រាតែ

$$\lim_{x\to 0} f(x) = f(0)$$

$$2 = \ln(m-1)$$

$$\ln(m-1) = \ln e^2$$

$$m-1 = e^2$$

$$\Rightarrow m = e^2+1$$

ដូចនេះ $\boxed{m = e^2+1}$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

4. រកប្រូបាបដែលគេចាប់បានឃ្លីស2 ឃ្លីខ្មៅ1

ឃ្លីសរុបមានចំនួន 8 ហើយគេចាប់យកម្តង3 គេបានករណីអាចៈ

$$n(S)=C(8;3)=\frac{8!}{(8-3)!3!}=\frac{6\times7\times8}{3\times2\times1}=56$$

តាង A ជា " ព្រឹត្តិការណ៍ដែលចាប់បានឃ្លីស2 ឃ្លីខ្មៅ1"

$$n(A)=C(3;2)\times C(5;1)=\frac{3!}{1!2!}\times5=3\times5=15$$

$$\Rightarrow P(A)=\frac{n(A)}{n(S)}=\frac{15}{56}$$

ដូចនេះ $\boxed{P(A)=\frac{15}{56}}$

5. គេអោយអនុគមន៍ $g(x)=\frac{x^2-3x-4}{x-2}$ មានក្រាប (c)

ក. កំណត់តម្លៃ a,b និង c

គេមាន $g(x)=ax+b+\frac{c}{x-2}$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$= \frac{ax(x-2)+b(x-2)+c}{x-2}$$

$$= \frac{ax^2-2ax+bx-2b+c}{x-2}$$

$$= \frac{ax^2-(2a-b)x-(2b-c)}{x-2}$$

តែ $g(x)=\frac{x^2-3x-4}{x-2}$

$$\Rightarrow \begin{cases} a=1 \\ 2a-b=3 \\ 2b-c=4 \end{cases} \Leftrightarrow \begin{cases} a=1 \\ b=-1 \\ c=-6 \end{cases}$$

ដូចនេះ $\boxed{a=1;b=-1;c=-6}$

ខ. រកអាស៊ីមតូតឈរ និងអាស៊ីមតូតទ្រេតនៃក្រាប (c).

ដោយ $\lim\limits_{x\to 2} g(x)=\lim\limits_{x\to 2}\frac{x^2-3x-4}{x-2}=\frac{-6}{0}=\pm\infty$

$\Rightarrow$ បន្ទាត់ $x=2$ ជាអាស៊ីមតូតឈរនៃក្រាប(c)

ដូចនេះ បន្ទាត់ $x=2$ ជាអាស៊ីមតូតឈរនៃក្រាប(c)

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$g(x)=x-1+\frac{-6}{x-2}$$

ដោយ $\lim_{x\to\pm\infty}\left(\frac{-6}{x-2}\right)=0$

$\Rightarrow$ បន្ទាត់ $y=x-1$ ជាអាស៊ីមតូតទ្រេតនៃក្រាប (c)

<u>ដូចនេះ</u> **បន្ទាត់ $y=x-1$ ជាអាស៊ីមតូតទ្រេតនៃក្រាប (c)**

គ. បង្ហាញថាចំណុច $I(2;1)$ ជាផ្ចិតឆ្លុះនៃក្រាប (c)

បើ $I(2;1)$ ជាផ្ចិតឆ្លុះនៃក្រាប (c) លុះត្រាតែ

$$g(4-x)+g(x)=2$$

គណនា $g(4-x)+g(x)$

$$=\frac{(4-x)^2-3(4-x)-4}{(4-x)-2}+g(x)$$

$$=\frac{16-8x+x^2-12+3x-4}{-x+2}+g(x)$$

$$=\frac{x^2-5x}{-(x-2)}+\frac{x^2-3x-4}{x-2}$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$= \frac{-(x^2 - 5x) + (x^2 - 3x - 4)}{x - 2}$$

$$= \frac{-x^2 + 5x + x^2 - 3x - 4}{x - 2}$$

$$= \frac{2x - 4}{x - 2} = \frac{2(x - 2)}{(x - 2)} = 2$$

ដូចនេះ

បង្ហាញថាចំណុច $I(2;1)$ ជាផ្ចិតឆ្លុះនៃក្រាប (c)

6. ក. កំណត់កូអរដោនេផ្ចិត និងកាំស្វ៊ែ (S)

$$(S): x^2 + y^2 + z^2 - 2x - 4y + 4z = 0$$

$$x^2 + y^2 + z^2 - 2x - 4y + 4z = 0$$

$$\Leftrightarrow (x^2 - 2x + 1) + (y^2 - 4y + 4)$$

$$+ (z^2 + 4z + 4) - 9 = 0$$

$$\Leftrightarrow (x - 1)^2 + (y - 2)^2 + (z + 2) = 3^2$$

មានទំរង់ $(x - a)^2 + (y - b)^2 + (z - c)^2 = R^2$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

នាំអោយ $a=1;b=2;c=-2$ និង $R=3$

ដូចនេះ | ផ្ចិត $I(1;2;-2)$ និងកាំ $R=3$

ខ. បង្ហាញថាប្លង់ (P) កាត់ស្វ៊ែ (S)

ប្លង់ (P) កាត់ស្វ៊ែ (S) លុះត្រាតែចំងាយពីផ្ចិតស្វ៊ែទៅប្លង់ (P) តូចជាងកាំR នៃស្វ៊ែ(S)

គេមានកាំស្វ៊ែ $R=3$ និង ប្លង់$(P): x+2y+2z+5=0$

ចំងាយ $d(I,(P))=\dfrac{|1+2\cdot 2+2(-2)+5|}{\sqrt{1^2+2^2+2^2}}=\dfrac{6}{3}=2$

ដោយ $d(I,(P))=2<R=3$

ដូចនេះ | បង្ហាញថាប្លង់ (P) កាត់ស្វ៊ែ (S)

គ. រកសមីការបណ្តាប្លង់ស្របនឹងប្លង់ (P) ហើយប៉ះស្វ៊ែ(S)

ប្លង់ (P) មានវ៉ិចទ័រណរម៉ាល់ $\vec{n}(1;2;2)$

តាង $M(x_0;y_0;z_0)$ ជាចំណុចដែលប៉ះស្វ៊ែ(S)

www.facebook.com/7khmer
Fb page : Entertainment And Knowledge

គេបាន $\overrightarrow{IM}(x_0-1;y_0-2;z+2)$

ដោយ $\vec{n}\|\overrightarrow{IM}$ គេបាន:

$$\vec{n}\times\overrightarrow{IM}=0$$

គេមាន $\vec{n}\times\overrightarrow{IM}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 1 & 2 & 2\\ (x_0-1) & (y_0-2) & (z_0+2)\end{vmatrix}$

$=[2(z_0+2)-2(y_0-2)]\vec{i}-[(z_0+2)-2(x_0-1)]\vec{j}$

$+[(y_0-2)-2(x_0-1)]\vec{k}=(2z_0-2y_0+8)\vec{i}$

$-(z_0-2x_0+4)\vec{j}+(y_0-2x_0)\vec{k}$

គេបាន $\begin{cases}2z_0-2y_0+8=0 & (1)\\ z_0-2x_0+4=0 & (2)\\ y_0-2x_0=0 & (3)\end{cases}$

តាម$(3)\Rightarrow y_0=2x_0$ យកទៅជំនួសក្នុង $(1);(2)$

$$\begin{cases}2z_0-4x_0+8=0\\ z_0-2x_0+4=0 \quad \times(-2)\end{cases}$$

$$0=0$$

ប្រព័ន្ធសមីការមានឫសរាប់មិនអស់ តាង $x_0=t;(t\in R)$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

តាម(3) $\Rightarrow y_0 = 2x_0 = 2t$

$(2) \Rightarrow z_0 = 2x_0 - 4 = 2t - 4$

យក $x_0; y_0; z_0$ ជំនួសក្នុងសមីការស្វ៊ែ(S) គេបាន:

$t^2 + 4t^2 + (2t-4)^2 - 2t - 8t + 4(2t-4) = 0$

$9t^2 - 16t - 10t + 8t + 16 - 16 = 0$

$9t^2 - 18t = 0$

$9t(t-2) = 0$

$\Rightarrow \left[\begin{array}{l} t = 0 \\ t - 2 = 0 \Rightarrow t = 2 \end{array}\right.$

ចំពោះ $t = 0 \Rightarrow M_1(0;0;-4)$

$t = 2 \Rightarrow M_2(2;4;0)$

ប្លង់ $(Q_1);(Q_2)$ កាត់តាមចំណុចរៀងគ្នា $M_1(0;0;-4)$ និង $M_2(2;4;0)$ ហើយកែងនឹង $\vec{n}(1;2;2)$ កំណត់ដោយ:

$\left[\begin{array}{l} (Q_1):(x-0)+2(y-0)+2(z+4)=0 \\ (Q_2):(x-2)+2(y-4)+2(z-0)=0 \end{array}\right.$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$\left[\begin{array}{l}(Q_1): x+2y+2z+8=0\\(Q_2): x+2y+2z-10=0\end{array}\right.$$

ដូចនេះ

$$\boxed{(Q_1): x+2y+2z+8=0; (Q_2): x+2y+2z-10=0}$$

វិញ្ញាសាទី៦

ប្រឡងជ្រើសរើសគ្រូមធ្យមសិក្សាបឋមភូមិ

សម័យប្រឡង: ១៦ តុលា ២០០៨

រយៈពេល: ២ ម៉ោង

1. ក. ដោះស្រាយសមីការ:

$$\frac{x-1}{1991}+\frac{x-5}{1987}+\frac{x+7}{1999}+\frac{x-11}{1981}=4$$

ខ. ដោះស្រាយសមីការ: $\ln\sqrt{x^2}=\sqrt{2\ln(-x)}$ ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

គ. ដោះស្រាយវិសមីការៈ $0 < \frac{x^2-2x-3}{x-2} < 4$

2. គេអោយអនុគមន៍ f កំណត់ដោយ $f(x) = \frac{5x^2+20x+6}{x^3+2x^2+x}$

ក. កំណត់តម្លៃ A, B, C ដើម្បីអោយ

$$f(x) = \frac{A}{x} + \frac{B}{x+1} + \frac{C}{(x+1)^2}$$

ខ. គណនា $F(x) = \int \frac{5x^2+20x+6}{x^3+2x^2+x}dx$

3. គេមានថង់ពីរ A និង B ។ ក្នុងថង់ A មានប៊ូលស1 និងប៊ូលខ្មៅ3 ។ ក្នុងថង់ B មានប៊ូលស5 និងប៊ូលខ្មៅ3 ។គេទាញយកប៊ូលមួយពីថង់ A និងប៊ូលមួយពីថង់ B រួចហើយប្តូរគ្នា ។

ក. រកប្រូបាបដើម្បីអោយថង់ A មានប៊ូលពណ៌ខ្មៅបន្ទាប់ពីប្តូរគ្នា

ខ. រកប្រូបាបដើម្បីអោយពណ៌ប៊ូលនៅក្នុងថង់នីមួយៗនៅដដែលបន្ទាប់ពីប្តូរគ្នា ។

4. ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $(E): y''+4y'+4y=0$

ខ. គេអោយសមីការឌីផេរ៉ង់ស្យែល$(F): y''+4y'+4y=-4x$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

កំណត់ចំនួនពិត a និង b ដែលអនុគមន៍ $\varphi : x \mapsto ax + b$ ជាចំលើយនៃ (F) ។

5. ក្នុងលំហប្រដាប់ដោយតំរុយអរតូណេរម៉ាល់វិជ្ជមាន $(0;\vec{i};\vec{j};\vec{k})$ គេអោយបួនចំណុច $A(-2;0;1)$; $B(0;10;3)$; $C(2;0;-1)$ និង $D(5;3;-1)$ ។

ក. សរសេរសមីការប្លង់ (P) កាត់តាមចំណុច $A; B$ និង C

ខ. សរសេរសមីការបន្ទាត់កាត់តាមចំណុច D ហើយកែងនឹង (P)

គ. សរសេរសមីការស្វ៊ែផ្ចិត D ហើយប៉ះប្លង់ (P) ។

6. គេអោយអនុគមន៍ f កំណត់ដោយ $f(x) = 3\sin x - 2\sin^3 x$

ក. សិក្សាអថេរភាព និងសង់ខ្សែកោង (c) តាង f

ខ. រកចំនួនពិត a និង b ដើម្បីអោយអនុគមន៍ F កំណត់ដោយ

$$F(x) = a\cos x + b\cos^3 x$$ ជាព្រីមីទីវនៃ f. ។

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ចំលើយ

1. ក. ដោះស្រាយសមីការ:

$$\frac{x-1}{1991}+\frac{x-5}{1987}+\frac{x+7}{1999}+\frac{x-11}{1981}=4$$

$$\Leftrightarrow \frac{x-1992+1991}{1991}+\frac{x-1992+1987}{1987}$$

$$+\frac{x-1992+1999}{1999}+\frac{x-1992+1981}{1981}=4$$

$$\Leftrightarrow \frac{x-1992}{1991}+1+\frac{x-1992}{1987}+1+\frac{x-1992}{1999}+1$$

$$+\frac{x-1992}{1981}+1=4$$

$$\Leftrightarrow (x-1992)\left(\frac{1}{1991}+\frac{1}{1987}+\frac{1}{1999}+\frac{1}{1981}\right)$$

$$+4=4$$

$$\Leftrightarrow (x-1992)\left(\frac{1}{1991}+\frac{1}{1987}+\frac{1}{1999}+\frac{1}{1981}\right)=0$$

$$\Leftrightarrow x-1992=0 \Rightarrow x=1992$$

ដូចនេះ $\boxed{x=1992}$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ខ. ដោះស្រាយសមីការ $\ln\sqrt{x^2}=\sqrt{2\ln(-x)}$

សមីការមានន័យកាលណា $\begin{cases}x^2>0\\ \ln(-x)\geq 0\end{cases}\Rightarrow x<0$

គេបាន:

$$\ln|x|=\sqrt{2\ln(-x)}$$

$$\ln(-x)=\sqrt{2\ln(-x)}$$

$$\ln^2(-x)=2\ln(-x)$$

$$\ln^2(-x)-2\ln(-x)=0$$

$$\ln(-x)[\ln(-x)-2]=0$$

$$\Rightarrow\left[\begin{array}{l}\ln(-x)=0\Rightarrow x=-1\\ \ln(-x)-2=0\end{array}\right.$$

$$\ln(-x)=2$$

$$\Rightarrow -x=e^2 \text{ ឬ } x=-e^2$$

__ដូចនេះ__ $\boxed{x=-1; x=-e^2}$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

គ. ដោះស្រាយវិសមីការៈ

$$0<\frac{x^2-2x-3}{x-2}<4$$

$$\Leftrightarrow \begin{cases} \dfrac{x^2-2x-3}{x-2}>0 & (1) \\ \dfrac{x^2-2x-3}{x-2}<4 \end{cases}$$

$$\frac{x^2-2x-3}{x-2}-4<0$$

$$\frac{x^2-2x-3-4(x-2)}{x-2}<0$$

$$\frac{x^2-6x+5}{x-2}<0 \quad (2)$$

បើ $x^2-2x-3=0$

$$\Rightarrow x=-1; x=3$$

បើ $x^2-6x+5=0$

$$\Rightarrow x=1; x=5$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

បើ $x-2=0 \Rightarrow x=2$

<u>តារាងសញ្ញា</u>

x	$-\infty \quad -1$	1	2	3	5	$+\infty$
x^2-2x-3	$+ \quad 0$	$-$	$-$	$- \quad 0$	$+$	$+$
x^2-6x+5	$+$	$+ \quad 0$	$-$	$-$	$- \quad 0$	$+$
$x-2$	$-$	$-$	$- \quad 0$	$+$	$+$	$+$
(1)	$- \quad 0$	$+$	$+$	$- \quad 0$	$+$	$+$
(2)	$-$	$- \quad 0$	$+$	$-$	$- \quad 0$	$+$
$(1)\cap(2)$						

$\Rightarrow x \in]-1;1[\cup]3;5[$

<u>ដូចនេះ</u>

$x=]-1;1[\cup]3;5[$ ជាចំលើយនៃវិសមីការ

2. គេអោយអនុគមន៍ $f(x)=\dfrac{5x^2+20x+6}{x^3+2x^2+x}$

ក. កំណត់តម្លៃ A,B,C

គេមាន $f(x)=\dfrac{A}{x}+\dfrac{B}{x+1}+\dfrac{c}{(x+1)^2}$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$= \frac{A(x+1)^2 + Bx(x+1) + Cx}{x(x+1)^2}$$

$$= \frac{A(x^2+2x+1) + B(x^2+x) + Cx}{x(x^2+2x+1)}$$

$$= \frac{(A+B)x^2 + (2A+B+C)x + A}{x^3+2x^2+x}$$

តែ $f(x) = \frac{5x^2+20x+6}{x^3+2x^2+x}$

នាំអោយ $\begin{cases} A+B=5 \\ 2A+B+C=20 \\ A=6 \end{cases} \Leftrightarrow \begin{cases} A=6 \\ B=-1 \\ C=9 \end{cases}$

ដូចនេះ $\boxed{A=6; B=-1; C=9}$

ខ. គណនា

$$F(x) = \int \frac{5x^2+20x+6}{x^3+2x^2+x}dx$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$=\int\left(\frac{6}{x}+\frac{-1}{x+1}+\frac{9}{(x+1)^2}\right)dx$$

$$=6\ln|x|-\ln|x+1|-\frac{9}{x+1}+c$$

<u>ដូចនេះ</u> $$F(x)=6\ln|x|-\ln|x+1|-\frac{9}{x+1}+c$$

3. ក. រកប្រូបាបដើម្បីអោយថង់ A មានប៊ូលខ្មៅបន្ទាប់ពីប្តូរគ្នា

តាង E "ជាព្រឹត្តិការណ៍ដែលថង់ A មានប៊ូលខ្មៅបន្ទាប់ពីប្តូរគ្នា"

ក្នុងថង់ A មានប៊ូលសុទ្ធតែពណ៌ខ្មៅបន្ទាប់ពីប្តូរកាលណា គេចាប់

បានប៊ូលស1 ពីថង់ A និងប៊ូលខ្មៅ1 ពីថង់ B

គេបាន: $P(E)=P(\text{ស})\times P(\text{ខ})$

$$=\frac{1}{4}\times\frac{3}{8}=\frac{3}{32}$$

<u>ដូចនេះ</u> $$P(E)=\frac{3}{32}$$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

ខ. រកប្រូបាបដើម្បីអោយពណ៌ប៊ូលនៅក្នុងថង់នីមួយៗនៅដដែល បន្ទាប់ពីប្តូរគ្នា

បន្ទាប់ពីប្តូរគ្នាពណ៌ប៊ូលនៅក្នុងថង់នីមួយៗនៅដដែល មានន័យថា គេចាប់បានប៊ូលពណ៌ដូចគ្នាពីក្នុងថង់នីមួយៗ ។

តាង F "ជាព្រឹត្តិការណ៍ពណ៌ប៊ូលនៅដដែលបន្ទាប់ពីប្តូរគ្នា"

គេបាន:

$$P(F) = \left(P(ស)_A \times P(ស)_B\right) + \left(P(ខ)_A \times P(ខ)_B\right)$$

$$= \left(\frac{1}{4} \times \frac{5}{8}\right) + \left(\frac{3}{4} \times \frac{3}{8}\right) = \frac{5}{32} + \frac{9}{32} = \frac{14}{32} = \frac{7}{16}$$

<u>ដូចនេះ</u> $\boxed{P(F) = \frac{7}{16}}$

4. ក. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល

$$(E): y'' + 4y' + 4y = 0$$

មានសមីការសំគាល់ $r^2 + 4r + 4 = 0$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$\Delta' = 4 - 4 = 0$$

$$\Rightarrow r_0 = r_1 = r_2 = -2$$

គេបាន $y = (Ax + B)e^{-2x}; (A, B \in R)$

ដូចនេះ $\boxed{y = (Ax + b)e^{-2x}}$ ជាចំលើយទូទៅនៃសមីការ (E)

ខ. កំណត់ចំនួនពិត a និង b

គេមាន: $(F): y''+4y'+4y = -4x$

$$\varphi(x) = ax + b$$
$$\Rightarrow \varphi'(x) = a$$
$$\Rightarrow \varphi''(x) = 0$$

ដោយ φ ជាចំលើយនៃ(F) នោះគេបាន:

$$\varphi''(x) + 4\varphi'(x) + 4\varphi(x) = -4x$$

$$0 + 4a + 4(ax + b) = -4x$$

$$4ax + 4a + 4b = -4x$$

$$\Rightarrow \begin{cases} 4a = -4 \\ 4a + 4b = 0 \end{cases} \Leftrightarrow \begin{cases} a = -1 \\ b = 1 \end{cases}$$

ដូចនេះ $\boxed{a = -1; b = 1}$

www.facebook.com/7khmer
Fb page : Entertainment And Knowledge

5. ក. សរសេរសមីការប្លង់(P) កាត់តាមចំណុច $A;B;C$

គេមាន $A(-2;0;1);B(0;10;3);C(2;0;-1)$ និង$D(5;3;-1)$

គេបាន $\overrightarrow{AB}(2;10;2);\overrightarrow{AC}(4;0;-2)$

$$\Rightarrow \overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ 2 & 10 & 2\\ 4 & 0 & -2\end{vmatrix}=-20\vec{i}+12\vec{j}-40\vec{k}$$

ប្លង់ (P) កាត់តាម $A(-2;0;1)$ ហើយកែងនឹងវ៉ិចទ័រ

$\overrightarrow{AB}\times\overrightarrow{AC}(-20;12;-40)$ កំណត់ដោយ:

$(P):-20(x+2)+12(y-0)-40(z-1)=0$

$(P):-20x+12y-40z-40+40=0$

$(P):-20x+12y-40z=0$

$(P):5x-3y+10z=0$

ដូចនេះ $\boxed{(P):5x-3y+10z=0}$

ខ. សរសេរសមីការបន្ទាត់ដែលកាត់តាមD ហើយកែងនឹងប្លង់(P)

បន្ទាត់ (d) កាត់តាម $D(5;3;-1)$ ហើយស្របនឹងវ៉ិទ័រ

$\overrightarrow{AB}\times\overrightarrow{AC}(-20;12;-40)$ កំណត់ដោយ:

www.facebook.com/7khmer
Fb page : Entertainment And Knowledge

$$(d):\begin{cases} x = x_0 + at \\ y = y_0 + bt \\ z = z_0 + ct;(t \in R) \end{cases} \Leftrightarrow \begin{cases} x = 5 - 20t \\ y = 3 + 12t \\ z = -1 - 40t \end{cases}$$

<u>ដូចនេះ</u>

$$\boxed{(d): x = 5 - 20t; y = 3 + 12t; z = -1 - 40t}$$

គ. សរសេរសមីការស្វ៊ែផ្ចិត D ហើយប៉ះប្លង់ (P)

